ACIAR Project ASEM/2006/130 “Production and marketing of maize And soybean in northwestern Cambodia”

# វិធានការចំរុះគ្រប់គ្រងកត្តាចង្រៃ

# សម្រាប់ដំណាំសណ្តែកសៀង នៅកម្ពុជា




**ប៊ប ម៉ាទីន ស្តេពហ្វេនី បែលហ្វេល & ទូច វ៉ាន់**

Primary Industries Innovation Centre, University of New England, Armidale NSW 2351, Australia, Phone: +61 2 6773 2869, Fax: +61 2 6773 3238
E-mail: bob.martin@une.edu.au


EUROPEAN UNION

Australian Government AusAID

Australian Government Australian Centre for International Agricultural Research

CCPMP Cambodia Crop Production & Marketing Project

care

# ផ្នែកទី ១

## សេចក្តីផ្តើមចំពោះ សិក្ខាសាលា និង អាយ ភី អឹម (IPM)

### សេចក្តីផ្តើមចំពោះសិក្ខាសាលា?

**សកម្មភាព ១. កំណត់ដំណាក់កាលលូតលាស់របស់សណ្តែកសៀង**

**គោលបំណង:** នៅចុងបញ្ចប់នៃសិក្ខាសាលា អ្នកចូលរួមនឹងអាចកំណត់ពីដំណាក់កាលលូតលាស់របស់ដើមសណ្តែកសៀង ។

**តំរូវការសំភារ:**

១. អ្នកចូលរួម គួរតែយកដើមសណ្តែកសៀង ៥ដើម ពីចំការផ្សេងៗ មុនពេលសិក្ខាសាលា ។

២. ឯកសារសិក្ខាសាលាជំពូកទី២ ទំព័រ៦-១៥

**សកម្មភាព ២. កំណត់សត្វល្អិត**

**គោលបំណង:** នៅចុងបញ្ចប់នៃសិក្ខាសាលា អ្នកចូលរួម នឹង អាចវែកញែករវាងសត្វមានប្រយោជន៍ និងសត្វចង្រៃ ។

**តំរូវការសំភារ:**

១. អ្នកចូលរួម គួរចាប់សត្វល្អិតច្រើនប្រភេទ ពីចំការរបស់ពួកគេ មុនពេលសិក្ខាសាលា

២. ដបផ្លាស្ទិចមានគំរបដោយទម្លុះប្រហោង

**សកម្មភាព ៣. ត្រួតពិនិត្យចំនួនសត្វក្នុងចំការ**

**គោលបំណង:** នៅចុងបញ្ចប់នៃសិក្ខាសាលា អ្នកចូលរួមនឹងអាចបង្ហាញកសិករផ្សេងៗទៀតពីរបៀបធ្វើសំណាកនៅចំការ ។

**តំរូវការសំភារ:**

១. សំណាញ់បក់ និង ផ្ទាំងក្រណាត់សំរាប់គោះ

២. សៀវភៅសរសេរ និងតារាងកត់ត្រា

**សកម្មភាព ៤.ការគណនាកំរិតមាត់ទ្វារសេដ្ឋកិច្ច និងពិភាក្សាអំពី ជំរើស អាយ ភី អឹម**

**គោលបំណង:** នៅចុងបញ្ចប់នៃ សិក្ខាសាលា នេះអ្នកចូលរួម នឹងអាច គណនាចំនុចកំណត់ត្រូវបាញ់ថ្នាំសំរាប់កត្តាចង្រៃនៅក្នុងសណ្តែកសៀង ។

**តំរូវការសំភារ:**

១. ឯកសារសិក្ខាសាលា ជំពូក ៧ - ៨ ។

២. សៀវភៅសរសេរ ម៉ាស៊ីនគិតលេខ និង តារាងកត់ត្រា ។

## ផ្តើមចំពោះ វិធានការចំរុះគ្រប់គ្រងកត្តាចង្រៃ (អា ភី អឹម - IPM)?

អាយ ភី អឹម (IPM) ពាក់ពន្ធ័ទៅនឹងការអនុវត្តន៍ ដោយរួមបញ្ចូលវិធីសាស្រ្តគ្រប់គ្រងច្រើនយ៉ាង ដើម្បីកាត់បន្ថយការបំផ្លាញពីកត្តាចង្រៃដោយការពារសត្វល្អិត មានប្រយោជន៍ហើយកាត់បន្ថយការប្រើប្រាស់ថ្នាំកំចាត់សត្វល្អិត ។



គោលបំណងរបស់ អាយ ភី អឹម (IPM) គឺដើម្បីរក្សាកត្តាចង្រៃនៅចំនួនតិច ដើម្បី កុំឱ្យពួកវាបំផ្លាញធ្ងន់ធ្ងរ ។ នេះធ្វើឡើងដោយការត្រួតពិនិត្យជាប្រចាំ ហើយពិចារណាយ៉ាងប្រុងប្រយ័ត្នចំពោះដំណាំ ព្រមទាំងទៅលើសកម្មភាពសត្វល្អិតមុនពេលការសំរេចចិត្តធ្វើថ្នាំកំចាត់សត្វល្អិត ។

## ផ្នែកទី២

## វគ្គលូតលាស់របស់ដំណាំសណ្តែកសៀង

វគ្គនៃវដ្តជីវិតរបស់សណ្តែកសៀង ត្រូវបានបែងចែកជាពីរ គឺ វគ្គលូតលាស់ និងវគ្គបន្តពូជ (មើលតារាងខាងក្រោម) ។

### ដំណាក់កាលលូតលាស់

VE – ដុះពន្លក

VC – កូទីឡេដុង

V1 – ខ្នែងទី ១

V2 – ខ្នែងទី ២

V3 - ខ្នែងទី ៣

V(n) - ខ្នែងទី អិន

### ដំណាក់កាលបន្តពូជ

R1 – កំណរកំណើតកញ្ចុំផ្កា

R2 – កញ្ចុំផ្កាពេលពេញ

R3 – កំណរកំណើតផ្លែ

R4 – ផ្លែពេញលេញ

R5 – ចាប់ផ្តើមដាក់គ្រាប់

R6 – ដាក់គ្រាប់ពេញលេញ

R7 – ចាប់ផ្តើមទុំ

R8 – ទុំពេញលេញ





## ២.១ ដំណាក់កាលលូតលាស់

### VE - ដុះពន្លក

គិតពីពេលសណ្តែកសៀងដុះចេញផុតពីដី



### V1 – ដំណាក់កាល ខ្នែងទី ១

គឺចាប់ផ្តើមនៅពេលស្លឹកឆែកបីចាប់ផ្តើម ដុះបន្ទាប់ពីស្លឹកនៃគ្រាប់ (កូទីលេដុង) និង លារស្លឹកព្រមទាំងខ្នែងក៏ចាប់ផ្តើមដុះ ចេញផងដែរ ។



### VC – ដុះពន្លកស្លឹកនៃគ្រាប់

គិតតាំងពីស្លឹកនៃគ្រាប់បានដុះចេញ និងបន្តលូតរហូតបានស្លឹកទោល ។



## V2– ដំណាក់កាល ខ្នែងទី ២

ដើមមានកំពស់ ១៥-២០ ស.ម និង មានខ្នែងបីស្លឹកពីរពុំទាន់លារ ។ សកម្មភាពចាប់យកអាសូត តាមរយៈបាក់តេរី គឺទើបនឹងតែចាប់ផ្តើមទេ ។



## V3– ដំណាក់កាល ខ្នែងទី ៣

ដើមមានកំពស់ ១៥-២០ ស.មនិងមានខ្នែងបីស្លឹកពីរពុំទាន់លារ ។សកម្មភាពចាប់យកអាសូតតាមរយៈបាក់តេរី គឺទើបនឹងតែចាប់ផ្តើមទេ ។




## V3-5– ដំណាក់កាល ខ្នែងទី ៣-៥



ដើមសណ្តែកសៀង មានកំពស់ ២០-២៥ ស.ម ខ្នែងស្លឹក ៤ (ស្លឹកតូចៗ ៣ មិនទាន់លារ)។

ដំណាក់កាលទី ៣ ដើមមានកំពស់ប្រហែល ២៥-៣០ ស.ម ខ្នែង ៦ ស្លឹក ។ ជាទូទៅនៅដំណាក់កាលទី ៥ ពន្លកប្រឈមនឹងមែកនៅចុងនៃដើម នឹងវិវឌ្ឍនទៅជាកញ្ចុំផ្កា ។

## V6 – ដំណាក់កាល ខ្នែងទី ៦



នៅដំណាក់នេះ សណ្តែកសៀង មានកំពស់ពី៣០-៣៥ ស.ម ខ្នែង ចំនួន៧ ។ ឫសព្រយោង បានដុះ តាមបណ្តោយជួរដេកនៅក្នុងដី ប្រវែងប្រហែល ៧៥ ស.ម ។ ដំណាក់កាលនេះ គឺ អាចឃើញ មានការបំផ្លាញដល់ដំណាំម្យ៉ាង ទៀតក្នុងករណី ស្លឹកមួយ សន្លឹក

## ២.២ ដំណាក់បន្តពូជ



## R1- ដំណាក់កាលចាប់ចេញផ្កា

ដើមសណ្តែកពន្លូតកំពស់រហូតដល់ពី៣៥-៤៥ ស.ម រីឯលក្ខណៈលូតលាស់ ដូចគ្នាទៅនឹងដើមនៅដំណាក់កាល V7-V10 ។ គេសង្កេត ឃើញមានផ្កាយ៉ាង តិចមួយនៅរាល់ខ្នែងនៃដើមដែរ ។



## R2 - ដំណាក់កាលចេញផ្កាពេលលេញ



សណ្តែកសៀងនៅកំពស់ប្រហែល៤៥-៥៥ ស.មគឺស្រដៀងគ្នាទៅនឹង V8-V12 ក្នុងដំណាក់កាលលូតលាស់ ។ ពេលចាប់ផ្តើមចេញផ្កាពេលលេញ ឃើញមានផ្ការីកនៅខ្នែង១ ក្នុងចំណោមខ្នែងចុងចំនួន២នៅលើដើម ។



## R3 - ដំណាក់កាលចេញផ្លែ

ដើមអាចមានកំពស់រហូតដល់៦០-៨០ ស.ម ដូចទៅ នឹងដំណាក់កាល V១១-V១៧ ។ផ្លែមួយនៅផ្នែកខាងលើខ្នែងបួន គឺមានប្រវែង៥ ម.ម ។ បញ្ហាសីតុណ្ហភាព និង សំណើមនៅដំណាក់កាលនេះអាចធ្វើឱ្យមានផលប៉ះពាល់ដល់ទិន្នផលតាមរយៈ ចំនួនផ្លែសរុប គ្រាប់ក្នុងមួយផ្លែនិងទំហំគ្រាប់ ។

## R4 - ដំណាក់កាលផ្លែពេញលេញ

ដំណាក់កាលនេះ បង្ហាញពីការលូតលាស់យ៉ាងលឿនរបស់ផ្លែ



ព្រមទាំងការចាប់ផ្តើម វិវឌ្ឍន របស់ គ្រាប់នៅដំណាក់កាលចាប់ផ្តើមដំបូងក្នុងដំណាក់កាលនេះ ។ នៅដំណាក់កាលនេះផ្លែមានប្រវែង ២ ស.ម នៅលើខ្នែងមួយនៃខ្នែងផ្នែកខាងលើទាំងបួននៅលើដើម ។ដំណាក់កាលនេះគឺជាពេលដែលសំខាន់បំផុត ចំពោះទិន្នផលគ្រាប់ ។

## R5 - ដំណាក់កាលចាប់ផ្តើមដាក់គ្រាប់

កំឡុងពេលដាក់គ្រាប់ ដំណាំត្រូវការទឹកច្រើនណាស់ ក៏ដូចជាសារធាតុចិញ្ចឹមពីដើមផងដែរ ។ ការបាត់បង់ស្លឹក ១០០% នៅដំណាក់កាលនេះ នឹងកាត់បន្ថយទិន្នផលប្រមាណជា





## R6 - គ្រាប់ពេញ



សណ្តែកមានពណ៌បៃតង និងដាក់គ្រាប់ពេញលេញ ម្យ៉ាងទៀតទំងន់សរុបខ្ពស់បំផុតក្នុងកំឡុងដំណាក់កាលនេះ ។ អត្រាការលូតលាស់របស់សណ្តែកមានលក្ខណៈលឿន ប៉ុន្តែចាប់ផ្តើមធ្លាក់ចុះនៅត្រឹមដំណាក់កាល R៦-៥ហើយកាន់តែខ្សោយ នៅ R៧ ។ ស្លឹកបន្តប្រែទៅជាពណ៌លឿង និងចាប់ផ្តើមទុំ



## R7 - ចាប់ផ្តើមទុំ

នៅដំណាក់កាលនេះទិដ្ឋភាពបាន នឹងកំពុងផ្លាស់ប្តូរពីពណ៌បៃតង ទៅពណ៌លឿងដោយរួមទាំងស្លឹកផ្លែ និងដើម ។

## R8 - ដំណាក់កាលទុំពេញលេញ

ប្រមាណជា៩៥% នៃផ្លែ



ឈានដល់ពណ៌ទុំ និងបន្ទាប់ពីប្រមូលផលរួច តំរូវឱ្យហាលសំងួតសណ្តែកសៀងយ៉ាងហោចណាស់នៅត្រឹមសំណើម១៥% ដែលតំរូវឱ្យហាលថ្ងៃប្រមាណជា៥-១០ថ្ងៃក្រោយពេលប្រមូលផលក្នុងករណីអាកាសធាតុក្តៅល្អ ។

# ផ្នែកទី ៣
# បច្ចេកទេសត្រួតពិនិត្យសត្វល្អិត

## ហេតុដូចម្តេចចាំបាច់ត្រូវពិនិត្យរកសត្វល្អិតនៅចំការ ???

បរិមាណសត្វល្អិត ដោយរួមទាំងសត្វល្អិតមានប្រយោជន៍ និងសត្វល្អិតចង្រៃគឺមានសារៈសំខាន់ណាស់ ដើម្បីជួយយើងធ្វើការសំរេចចិត្តត្រឹមត្រូវ ក្នុងការកំចាត់ ។

## តើត្រូវធ្វើដូចម្តេចដើម្បីកំណត់អំពីបរិមាណនៅក្នុងចំការរបស់អ្នក?

មានវិធីសាស្រ្ត បី គេកំពង់ប្រើដើម្បីត្រួតពិនិត្យមើលសត្វល្អិតៈ
១.ការពិនិត្យដោយភ្នែក ២.ដោយគោះដាក់ផ្ទាំងក្រណាត់ ៣.សំណាញ់(កន្ត្រង)បក់

### ១. ការពិនិត្យដោយភ្នែក



កំនត់ជួរសណ្តែកសៀងប្រវែង ០.៥ ម ត្រូវត្រួតពិនិត្យឱ្យបានម៉ត់ចត់តាំងពីគល់ដល់ចុងរបស់ដំណាំ។ រាល់ផ្ទៃខាងក្រៅ និងខាងចុងដំណាំ គួរតែពិនិត្យផងដែរ ព្រមទាំងនៅផ្ទៃក្រោមក្បែរដី ។

### ២. ការពិនិត្យដោយផ្ទាំងក្រណាត់គោះ



ប្រើផ្ទាំងក្រណាត់ទំហំ ១ ម៉ែត្រ លាតត្រដាងផ្ទាំង ក្រណាត់ស្របនឹងជួរដំណាំប្រវែង ១ ម៉ែត្ររួចផ្តេកដើមសណ្តែកលើផ្ទាំងក្រណាត់ បន្ទាប់មកគោះដើមសណ្តែកយ៉ាងស្វាហាប់ ដើម្បីទំលាក់សត្វល្អិត ។ ធ្វើរបៀបនេះ យើងអាចពិនិត្យ

ឃើញសត្វល្អិតចំនួនច្រើនជាង ២ ដង បើធៀបទៅនឹងការពិនិត្យដោយភ្នែក ។

### ផ្នែកទី៣ ការពិនិត្យដោយប្រើសំណាញ់បក់



សំណាញ់បក់ មានទំហំអង្កត់ផ្ចិតប្រហែល ៤០ស.ម ជំរៅ ៦០ ស.ម ប្រវែងដងកាន់ ១ ម ។បក់ចំនួន ១០ ដង តាមបណ្តោយជួរដំណាំប្រហែល ១០ ម ។

# តារាងកត់ត្រាទិន្នន័យនៅចំការ របស់ អា ភី អឹម ដំណាំសណ្តែកសៀង

អ្នកប្រមូលទិន្នន័យ: ______ កាលបរិច្ឆេទ: ______

ខេត្ត: ______ ស្រុក: ______ ឃុំ: ______

ភូមិ: ______ កសិករ: ______ ហិចតា: ______

ដំណាក់កាលដំណាំ: ______ កំពស់: ______

ស្លឹកខូច (%): ______ ដើម/ផ្លែបានខូចខាត: ______

វិធីសាស្ត្រធ្វើសំណាកដែលប្រើ (✓): ☐ ដោយភ្នែក[2] ☐ សំណាញ់បក់[3] ☐ ផ្ទាំងក្រណាត់[4] ☐

| កត្តាចង្រៃ | ដំ.កាល[1] | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ស.រ |
|---|---|---|---|---|---|---|---|---|---|---|---|---|
|   | ត<br>ម<br>ធំ | | | | | | | | | | | |
|   | ត<br>ម<br>ធំ | | | | | | | | | | | |
|   | | | | | | | | | | | | |
|   | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
|  | ជ<br>ព | | | | | | | | | | | |
|  | ជ<br>ព | | | | | | | | | | | |
| ផ្សេងៗ | | | | | | | | | | | | |

១. - សំរាប់កូនដង្កូវមេអំបៅ: ត=តូច (ប្រវែង ១០ម.ម )ម=មធ្យម (ប្រវែង ១០-២០ម.ម ) ធំ (.ប្រវែង ២០ម.ម ) ។

- សំរាប់ ស្រឹង: ជ=ជំទង់, ព=ពេញវ័យ

២. ធ្វើសំណាកដោយភ្នែក: ជ្រើសរើសសំណាក ០.៥ម ប្រវែងជួរ និងត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ កំពស់ ០.៥ ម ពីក្រោម ដល់លើ ។

៣. ធ្វើសំណាកដោយសំណាញ់បក់: បក់សំណាញ់ ១០ ដង តាមបណ្ដោយជួរ (ប្រហែល ១០ ម)

៤. ធ្វើសំណាកផ្ទាំងក្រណាត់គោះ ជ្រើសរើស ជួរ ១ ម ត្រដាងផ្ទាំងក្រណាត់ដោយកែកុនតាមគន្លងនិងអង្រន់ដើមដំណាំ ដាក់លើក្រណាត់ផ្ទាំង ។

## តារាងកត់ត្រាទិន្នន័យនៅចំការ របស់ អា តី អឹម ដំណាំសណ្ដែកសៀង (ត)

វិធីសាស្ត្រធ្វើសំណាកដែលប្រើ ( √ ) ☐ដាយភ្នែក[២] ☐បំណាញ់បក់[៣]▫ ☐ផ្ទាំងក្រណាត់[៤] ▫

| សត្វមានប្រយោជន៍ | ដំណាក់កាល[១] | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ស.រ |
|---|---|---|---|---|---|---|---|---|---|---|---|---|
|  | | | | | | | | | | | | |
|  | | | | | | | | | | | | |
|  | | | | | | | | | | | | |
|  | | | | | | | | | | | | |
|  | | | | | | | | | | | | |
| ផ្សេងៗ | | | | | | | | | | | | |

១. ធ្វើសំណាកដោយភ្នែក ជ្រើសរើសសំណាក ០.៥ ម ប្រវែងជួរ និងត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ កំពស់ ០.៥ ម ពីក្រោមដល់លើ។

៣. សំណាញ់បក់: បក់សំណាញ់ ១០ ដង តាមបណ្ដោយជួរ (ប្រហែល ១០ ម)

៤. ផ្ទាំងក្រណាត់គោះ  ជ្រើសរើសជួរ ១ ម ត្រដាងផ្ទាំងក្រណាត់ ដោយកែកុនតាមគន្លង និងអង្រន់ដើមដំណាំដាក់លើផ្ទាំងក្រណាត់

# ផ្នែកទី៤

# អំពីសត្វល្អិតចង្រៃ និងសត្វល្អិតមានប្រយោជន៍

## ៤.១ សត្វល្អិតចង្រៃចំពោះដំណាំ



**លក្ខណៈទូទៅ: ឈ្មោះ ដង្កូវស៊ីរូងផ្លែ**

កូនដង្កូវញាស់ថ្មី មានពណ៌ស និងពណ៌ស្រអាប់នៅផ្នែកខាងមុខ។ កូនដង្កូវ កាន់តែមានពណ៌ស្រអាប់ និងចំណុចស្រអាប់។ ដង្កូវពេញវ័យមានគំនូសបន្ទាត់នៅសងខាងដងខ្លួន។

**ការបំផ្លាញ:**

ការបំផ្លាញភាគច្រើន នៅផ្នែកខាងចុង ត្រួយ ផ្កា និងផ្លែ។ កូនដង្កូវ ក៏ស៊ីបំផ្លាញស្លឹក ប៉ុន្តជាទូទៅ មិនជាសំខាន់ទេ។

**លក្ខណៈទូទៅ:** ឈ្មោះ ដង្កូវទ័ព



ដង្កូវពេញវ័យមានត្រីកោណពណ៌ខ្មៅ តំរៀបេះជាជួរនៅលើខ្នងសងខាង ហើយដងខ្លួនលាតសន្ធឹងដល់ក្បាល។ ដង្កូវមានប្រវែង ៣០ មម និងមេអំបៅ ២៥ មម។ សត្វនេះ ពងជាក្រុមចំនួនរហូតដល់ ៣០០ និងគ្របដណ្តប់ដោយសក់ពណ៌ត្នោតដូចកន្ទេល។

**ការបំផ្លាញ:**

ដង្កូវបំផ្លាញត្រួសៗលើស្លឹក និងបំផ្លាញខ្លាំងត្រួយ និងផ្កា។ ការបំផ្លាញនៅគ្រប់ផ្នែកទាំងអស់របស់ដំណាំ



លក្ខណៈទូទៅ: **ឈ្មោះ សត្វស្លាបរឹង**

សត្វពេលវ័យប្រវែង ៣ មម មានស្លាបរឹង ពណ៌លឿងក្រហមស្រគាំ ឬពណ៌ត្នោតក្រហមស្រគាំព្រមទាំងមានចំនុចពណ៌សពីរនៅស្លាបទាំងសងខាង ។

ការបំផ្លាញ:

សត្វពេញវ័យស៊ីបំផ្លាញស្លឹកទាំងមូល គិតចាប់ទាំងពីដំណាក់កាលកូនដំណាំ រហូតដល់ផ្លែ ។

ការបំផ្លាញទៅ

លើដំណាំ សណ្តែកដី សណ្តែកបាយ សណ្តែកសៀង ដំឡូងជ្វា និងផ្កាឈូករ័ត្ន ។



លក្ខណៈទូទៅ: ឈ្មោះ ចង្រិត

ពពួកចង្រិត អាចកាន់តែមានចំនួនច្រើនឡើង ហើយអាច ធ្វើការបំលាស់ទីជាហ្វូងបានទៀតផង ។

ការបំផ្លាញ:

សត្វពេញវ័យ និងជំទង់ ស៊ីស្លឹក និងដើមដំណាំនៅគ្រប់ ដំណាក់កាលទាំងអស់ ។ ប្រភេទដំណាំដែលបំផ្លាញមាន ពោត សណ្តែកបាយ សណ្តែកសៀង សណ្តែកដី ។



លក្ខណៈទូទៅ: ឈ្មោះ ស្រឹងបៃតង

សត្វពេញវ័យ មានពណ៌បៃតងភ្លឺ ហើយសត្វជំទង់ ប្តូរពណ៌ខណៈពេលដែលវាលូតលាស់: ដំ.កាលទី១ ពណ៌ទឹកក្រូច ដំ.កាលទី ២ ពណ៌ត្នោត ដំ.កាលទី៣ ពណ៌ខ្មៅ ដំ.កាលទី ៤-៥ ភាគច្រើន ពណ៌បៃតង និងខ្មៅ ។

ការបំផ្លាញ:

សត្វពេញវ័យ និងជំទង់ ចោះទំលុះនិងប៊ឺតជញ្ជក់ផ្លែ និងគ្រាប់កំពុងលូតលាស់ នៅដំណាក់កាលចេញ កញ្ចុំផ្ការហូតដល់ផ្លែដាក់គ្រាប់ លើប្រភេទដំណាំ ដូចជា ពោត សណ្តែកបាយ សណ្តែកសៀង សណ្តែកដី សណ្តែកអង្គុយ ។



លក្ខណៈទូទៅ: ឈ្មោះ ស្រឹងបៃតង

សត្វមានប្រវែង ៩ មម ពណ៌បៃតង និងពណ៌លឿងភ្លឺ ជាមួយនឹងពណ៌លឿង ឬក្រហមមួយកោងកាត់ស្មានិងគែមនៃដងខ្លួន ។

ការបំផ្លាញ:

សត្វពេញវ័យ និងជំទង់ ចោះទំលុះ និងប៊ឺតជញ្ជក់ផ្លែ និងគ្រាប់កំពុងលូតលាស់ នៅដំណាក់កាលចេញ កញ្ចុំផ្កា រហូតដល់ផ្លែដាក់គ្រាប់ លើប្រភេទដំណាំ

ដូចជា ពោត សណ្តែកបាយ សណ្តែកសៀង សណ្តែកដី សណ្តែកអង្គុយ ។





លក្ខណៈទូទៅ: ឈ្មោះ ស្រឹងពណ៌ត្នោត

សត្វពេញវ័យ មានឆ្នូតពណ៌លឿងនៅសងខាង ។ សត្វជំទង់ មានរូបរាងស្រដៀងគ្នាទៅនឹងស្រមោច ហើយពងមានពណ៌ត្នោតភ្លឺ ។

ការបំផ្លាញ:

សត្វពេញវ័យ និងជំទង់ ចោះទំលុះ និងបឺតជញ្ជក់ផ្លែ និង គ្រាប់កំពុងលូតលាស់ នៅដំណាក់កាលចេញផ្ការហូតដល់ផ្លែដាក់គ្រាប់ លើប្រភេទដំណាំ ដូចជា សណ្តែកបាយ សណ្តែកសៀង សណ្តែកអង្គុយ ។



លក្ខណៈទូទៅ: ឈ្មោះ ស្រឹងសណ្តែកបន្លា

សត្វពេញវ័យ មានប្រវែងទៅនឹងស្រឹងពណ៌ត្នោតដែរ។ ពួកវា មានពណ៌ត្នោតក្រហមស្រគាំ ជាមួយនឹងអុចពណ៌នៅលើខ្នងចំនួន ៣ ។

ការបំផ្លាញ:

សត្វពេញវ័យ និងជំទង់ ចោះទំលុះ និងបឺតជញ្ជក់ផ្លែ និង គ្រាប់កំពុងលូតលាស់ នៅដំណាក់កាលចេញផ្ការហូតដល់ផ្លែដាក់គ្រាប់ លើប្រភេទ

ដំណាំដូចជាសណ្តែកបាយ សណ្តែកសៀង សណ្តែកអង្គុយ ។

## ៤.២ សត្វល្អិតមានប្រយោជន៍ចំពោះដំណាំ



លក្ខណៈទូទៅ: ឈ្មោះ អណ្តើកមាស

សត្វនេះមានប្រវែង៣-៦ មម ទទឹក៣-៥ មម ។ ដងខ្លួន មានពណ៌ទឹកក្រូចស្រអាប់ពណ៌ក្រហមស្រាលពណ៌លឿង និងពណ៌ស៊ីជំពូ ។ មានចំនុចខ្មៅចំនួន ៦ នៅលើស្លាប ព្រមទាំងបន្ទាត់ក្រវិកក្រវ៉ក់ និងចំនុចខ្មៅនៅផ្នែកខាងក្រោយ ។

សារៈប្រយោជន:

អណ្តើកមាស គឺជាព្រេដាទ័រដ៏សំខាន់ចំពោះពពួកចៃព្រមទាំងពងសត្វល្អិត និងកូនដង្កូវជាច្រើនទៀត ។



លក្ខណៈទូទៅ: ឈ្មោះ រុយ សំកាំង

សត្វនេះ មានស្រដៀងគនាទៅនឹងសត្វឃ្មុំនិងសត្វឱម៉ាល់ហើយ ការហើរសំកាំងដូចជាយន្តហោះ ។ សត្វពេញវ័យ ស៊ីទឹកដម និងលំអងផ្កា ។ សត្វពេញវ័យ មានពណ៌ខ្មៅ និងលឿងឆ្នូតកាត់ដងខ្លួនរាប ដែលមានប្រវែង ៤-៧ មម ។

សារៈប្រយោជន:

ស៊ីពពួកចៃ



លក្ខណៈទូទៅៈ ឈ្មោះ ស្រឹងខែល

សត្វពេញវ័យមានប្រវែង ១២ មម និងមានពណ៌ត្នោត ប្រផេះដងខ្លួនរាងដូចខែល ។ សត្វជំទង់ មានពណ៌ប្រផេះចាស់ ជាមួយនឹងរាងដូចចញ្ចៀន ពណ៌ក្រហម នៅលើខ្នង ។

សារៈប្រយោជន៍ៈ

សត្វពេញវ័យ និងជំទង់ជ្រេរ ប្រើម្ជុលបឺតពពួកដង្កូវ ។ រីឯសត្វជំទង់ស្ទើរ ជញ្ជក់រុក្ខរសរបស់ដំណាំ ។



លក្ខណៈទូទៅៈ ឈ្មោះ ពពួកឱម៉ាល់ព្រៃដាទ័រ

សារៈប្រយោជន៍ៈ

ពពួកឱម៉ាល់ព្រៃដាទ័រ គឺទូទៅ ប្រេដាទ័រដ៏សំខាន់ ចំពោះពពួកដង្កូវដោយស៊ីទំពារ រួចពងដាក់ក្នុងខ្លួនសត្វដោយ ញ៉ាស់ជាកូនដង្កូវនៅក្នុងសំបុក ។ ភាគច្រើនឱម៉ាល់ព្រៃដាទ័រធ្វើសំបុកកោសិកាភក់ដាក់លើពពួកដង្កូវ ដែលមិន ឱ្យធ្វើចលនាបាន បន្ទាប់មកពងដាក់ក្នុងសំបុកនេះ ។



លក្ខណៈទូទៅៈ ឈ្មោះ កណ្តាបបុកស្រូវ

សារៈប្រយោជន៍ៈ

សត្វនេះ ចាប់សត្វដ៏ទៃទៀតជាអាហារ និងពេលខ្លះ កាត់ស្លឹកដំណាំ ប៉ុន្តែជាទូទៅមិនដែលបំផ្លាញដល់កំរិតមាត់ទ្វារសេដ្ឋកិច្ច ។

# ផ្នែកទី ៥
# ចំនុចមាត់ទ្វារសេដ្ឋកិច្ច

គឺនៅកំរិតដែលចំនួនកត្តាចង្រៃទំនងជាបណ្តាលឱ្យខូចដែលស្មើទៅនឹងការចំណាយលើការកំចាត់ ។ កសិករគួរតែបាញ់ថ្នាំ ខណៈពេលដែលចំនួននៃកត្តាចង្រៃខ្ពស់ជាងមាត់ទ្វារសេដ្ឋកិច្ច ។ ចំនុចមាត់ទ្វារសេដ្ឋកិច្ចនៃការបំផ្លាញ និងកត្តាចង្រៃ គឺជាចំនុចដ៏សំខាន់មួយរបស់ អាយ ភី អឹម ។

កសិករមិនគួរបាញ់ថ្នាំនៅពេលដែលការបំផ្លាញនៅក្រោមមាត់ទ្វារសេដ្ឋកិច្ច មូលហេតុ:

- ខ្ជះខ្ជាយថវិការ
- អាចបង្កើននូវចំនួនកត្តាចង្រៃកាន់តែច្រើន ប្រសិនបើសត្វមានប្រយោជន៍ត្រូវសំលាប់មុន និងដោយសារតែ
- បង្កើនការបង្កើតឱ្យមានភាពសមទៅនឹង ថ្នាំកំចាត់សត្វល្អិត ។

  មាត់ទ្វារសេដ្ឋកិច្ច ចំពោះការបាត់បង់ស្លឹកសណ្តែកសៀង គឺ:
- ដំណាក់កាលនៅចន្លោះពេលលូតលាស់ និងចេញផ្កាចំនុចមាត់ទ្វារសេដ្ឋកិច្ច ៣៥% នៃការបាត់បង់ស្លឹក
- ដំណាក់កាលដាក់គ្រាប់ដំបូង: កំរិតមាត់ទ្វាសេដ្ឋកិច្ចអាចធ្លាក់ជាលំដាប់ដល់ ១៥%នៃការបាត់បង់ស្លឹក



Defoliation in soybeans ranging from 5% to 45%.

កំរិតមាត់ទ្វារសេដ្ឋកិច្ចថ្មីមួយ សំរាប់ដង្កូវ ស៊ីរូងផ្លែ ក្នុងដំណាក់កាលលូតលាស់ របស់សណ្តែកសៀងត្រូវបានកំនត់ក្នុងកំរិត កូនដង្កូវចំនួន៨ក្នុង១ម២ និងជំនួសឱ្យកំរិតបាត់បង់ស្លឹកពីមុន ៣៥%។

## ចំនុចមាត់ទ្វារសេដ្ឋកិច្ច-ការបំផ្លាញផ្លែ

ប្រភេទសត្វជញ្ជក់ដែលបំផ្លាញខ្លាំង គឺជាស្រឹងបៃតង និងសត្វល្អិតជញ្ជក់ផ្សេងទៀត គឺស្រឹងសណ្តែកពណ៌ត្នោត ។ដំណាំនៅតែមានគ្រោះថ្នាក់ដោយការវាយប្រហារ ពីស្រឹងជញ្ជក់ផ្លែរហូតជិតដល់ពេលប្រមូលផល ហើយបើទោះបីជា គ្រាប់សណ្តែកកំពុងទុំនៅក្នុងផ្លែក៏ដោយក៏អាចបំផ្លាញដែរ ។









### ចំណុចកំណត់ត្រូវប្រាញ់ថ្នាំ

- នៅចន្លោះពេលលូតលាស់ និងចេញផ្កា: ស្រឹងបៃតង ១ក្បាល ក្នុង ១ ម២
- ដំណាក់កាលផ្លែអាចបេះហូបបាន: ស្រឹងបៃតង ០.៣៣ ក្បាល ក្នុង ១ ម២

សំគាល់: ត្រួតពិនិត្យមើលដំណាំនៅចន្លោះពេល ៧-៩ ព្រឹក នៅពេលស្រឹងបៃតងទំនងជាមានសកម្មភាព ។

### ការគណនាចំនួនសត្វល្អិតក្នុង ១ ម២

ដើម្បីកំណត់ចំនួនពិនិត្យប្រាកដរបស់សត្វល្អិត ក្នុង ០.៥ ម២ របស់ជួរដំណាំ កត្តាកែតម្រូវបន្តបន្ទាប់ ត្រូវបង្កើតឡើងដោយ (*Duffield etal.2005*) មើលដោយភ្នែក(១.៥៨) ផ្ទាំងក្រណាត់(១.៣៨) និងសំណាញ់បក់(១.៨៨) ។

ឧ. ក្រោយពីធ្វើសំណាកពិនិត្យមើលដោយភ្នែក យើងទទួលបានមធ្យមរបស់សត្វល្អិតមានចំនួន ០.៥ នៃលទ្ធផលធ្វើសំណាក ។ យើងបានចំនួនបានកែតម្រូវចំពោះសំណាកមើលពិនិត្យដោយភ្នែក ត្រូវជា ០.៧៧ (០.៥ X ១.៥៨) ។

ម្យ៉ាងទៀត ដើម្បីបំលែងចំនួននេះទៅជា ចំនួន/១ម២ យើងត្រូវដឹងប្រវែងចន្លោះជួរ ។ ឧ. ចន្លោះជួរសណ្តែកសៀងប្រវែង ០.៨ ម ។ ដូច្នេះចំនួនសត្វល្អិតក្នុង ១ម២ គឺ (០.៥ X ១.៥៨) X ៥ = ៣.៩ (សត្វល្អិត ក្នុងផ្ទៃ ១ ម២) ។

### មាត់ទ្វារសេដ្ឋកិច្ច

មើលតារាងបានបង្ហាញ (នៅខាងក្រោម)សំរាប់:

- កូនដង្កូវ នៅដំណាក់កាលលូតលាស់
- កូនដង្កូវនៅដំណាក់កាលដាក់គ្រាប់
- ស្រឹងបៃតងនៅដំណាក់កាលនៅចន្លោះលូតលាស់ និងចេញផ្កា
- ស្រឹងបៃតងនៅតំណាក់កាលសណ្តែកអាចហូបបាន

អ្នកអាចគណនា មធ្យមភាគចំពោះសំណាកដូចក្នុងឧទាហរណបន្តបន្ទាប់ ។ ប្រសិនបើ ១០ សំណាក (ធ្វើឡើងដោយភ្នែក ផ្ទាំងក្រណាត់ និងសំណាញ់បក់) ត្រូវយកសំណាក និង កត់ត្រាចំនួនសត្វល្អិតទាំងអស់ បន្ទាប់មក មធ្យម គឺមាន ប្រហែល៥/១០ ឬ ០.៥ ។

បន្ទាប់មក អ្នកអាចប្រើតារាង (ខាងក្រោម) ដើម្បីបំលែងជាមូលដ្ឋាននូវចំនួន សត្វល្អិតក្នុង ១ម២ ។ ឧទាហរណ៍ ដង្កូវស៊ីរូងផ្លែសណ្តែកនៅដំណាក់កាល លូតលាស់ ការធ្វើសំណាក់ដោយភ្នែក ស្មើនឹង ៣.៩ ក្នុង ១ ម$^{២}$ (ដូចបានគណនា ខាងលើ) ។ ចំនួននេះ នៅទាបជាងចំនុចមាត់ទ្វារសេដ្ឋកិច្ច ហើយអ្នកនឹងមិនបាញ់ ថ្នាំទេ ។

សំគាល់: ចំនួនក្នុងផ្ទៃតារាងពណ៌បៃតង គឺនៅទាបជាងមាត់ទ្វារសេដ្ឋកិច្ច និងចំនួននៅពណ៌ ក្រហមនៅលើចំនុចមាត់ទ្វារសេដ្ឋកិច្ច ។

តារាង ១. កូនដង្កូវស៊ីផ្លែសណ្តែក-ដំណាក់កាលលូតលាស់ (៨/ម$^{២}$)

| មធ្យមសំណាក | ដោយភ្នែក | ផ្ទាំងក្រណាត់ | សំណាញ់បក់ |
|---|---|---|---|
| ០.៥ | ៣.៩ | ៣.៥ | ៤.៦ |
| ១ | ៧.៧ | ៦.៩ | ៩.២ |
| ១.៥ | ១១.៦ | ១០.៤ | ១៣.៨ |
| ២ | ១៥.៤ | ១៣.៨ | ១៨.៤ |

តារាង ២. កូនដង្កូវស៊ីផ្លែសណ្តែក-ដំណាក់ដាក់គ្រាប់ (២/ម$^{២}$)

| មធ្យមសំណាក | ដោយភ្នែក | ផ្ទាំងក្រណាត់ | សំណាញ់បក់ |
|---|---|---|---|
| ០.១ | ០.៨ | ០.៧ | ០.៩ |
| ០.២ | ១.៥ | ១.៤ | ១.៨ |
| ០.៣ | ២.៣ | ២.១ | ២.៨ |

តារាង ៣. កូនដង្កូវស៊ីផ្លែសណ្តែក- នៅចន្លោះវគ្គលូតលាស់ និងចេញផ្កា( ១/ម$^{២}$ )

| មធ្យមសំណាក | ដោយភ្នែក | ផ្ទាំងក្រណាត់ | សំណាញ់បក់ |
|---|---|---|---|
| ០.០៥ | ០.៤ | ០.៤ | ០.៤ |
| ០.១០ | ០.៨ | ០.៨ | ០.៨ |
| ០.១៥ | ១.២ | ១.២ | ១.២ |
| ០.២០ | ១.៥ | ១.៥ | ១.៥ |

# ផ្នែកទី ៦
# ថ្នាំកំចាត់សត្វល្អិត និង ការប្រើប្រាស់

## តើអ្វីជា ថ្នាំពុលកសិកម្មកំចាត់សត្វល្អិត?

ជាសារធាតុគីមី ប្រើសំលាប់ សត្វល្អិត







## របៀបដែលថ្នាំធ្វើសកម្មភាព (សំលាប់សត្វល្អិត)

ពុលដោយប៉ះផ្ទាល់ និងពុលដោយជ្រាបចូលក្នុងខ្លួន

## ប្រភេទថ្នាំកំចាត់សត្វល្អិត និងកំរិតជាតពុល

ជាតិពុលកាន់តែខ្លាំង

- អ័រហ្គេណូផូសេត (Organophosphates)
- អ័រហ្គេណូផូសេត (Organochlorides)
- ការប៉ាម៉ាត (Carbamates)
- ស៊ីនសិធីក ភាយរ៉េស្រយ្យ(Synthetic Pyrethroids)
- ជីវសាស្រ្ត (Boilogicals)

ជាតិពុលកាន់តែខ្សោយ

# ថ្នាំពុលកសិកម្មកំចាត់សត្វល្អិត អាចរកបាននៅប្រទេសកម្ពុជា

## ជំងឺបង្កឡើងដោយបាក់តេរី បាស៊ីលឡឹស ស្វូរីងជៀនស៊ីស (*Heliothis*)

| ឈ្មោះក្រុមហ៊ុន | បរិមាណខ្ចប់ | % កំហាប់ | ស្លាកសញ្ញា | លីត្រ/ហិចតា |
|---|---|---|---|---|
| Aztron | 1.0-4.0 | 10 g | 16 | Vietnamese |
| Biobit 52BFC | 100 g | 32 | Vietnamese | 0.5-2.0 |
| Dipel 6.4 DF | 10 g | 16 | Vietnamese | 1.0-4.0 |
| Delfin WG | 10 g | 32 | Vietnamese | 0.5-2.0 |
| Fowarbit 16.00 IU | 100 g | 16 | English | 1.0-4.0 |
| Sandoz PH | 1000 g | 32 | English | 0.5-2.0 |
| Thuricide HP | 1000 g | 32 | Thai | 0.5-2.0 |

## អាល់ហ្វា-សាយតឺមិស្រីន (*AlphaCypermethrin_ Heliothis*)

| ឈ្មោះក្រុមហ៊ុន | លីត្រ/ហិចតា | បរិមាណខ្ចប់ | % កំហាប់ | ស្លាកសញ្ញា |
|---|---|---|---|---|
| Fastocid 5 EC | 100 ml | 5 | Vietnamese | 0.35 |
| Fastox 5 EC | 100 ml | 5 | Vietnamese | 0.35 |
| Motox 5 EC | 100, 480 ml | 5 | Vietnamese | 0.35 |
| Sapan alpha 5 EC | 480 ml | 5 | Vietnamese | 0.35 |
| Tilt alpha 5 EC | 480 ml | 5 | Vietnamese | 0.35 |
| Vifast 5 ND | 100 ml | 5 | Vietnamese | 0.35 |





**ពួកមេអំបៅ/កូនដង្កូវ**

**( *Heliothis*)**

## សាយតឺមិស្រីន-ពួកមេអំបៅ/កូនដង្កូវ (*Cypermethrin _ Heliothis*)

| | | | | |
|---|---|---|---|---|
| Andoril 250EC | 1L | 25 | Vietnamese | L/ha |
| Carmethrin25 EC | 100 ml | 25 | Vietnamese | 0.35 |
| Chix | 500 ml | 25 | Thai | 0.35 |
| Cykker 10 | 100 ml | 10 | Thai | 0.875 |
| Cyrus 25 | 100 ml | 25 | Vietnamese | 0.35 |
| Frong 35 | 100, 500, 1000ml | 35 | Thai | 0.25 |
| Koutnok 10 | 100, 250, 500, 1000ml | 10 | Thai | 0.875 |
| Luxenpob | 100 ml | 10 | Thai | 0.875 |
| Luxentoy 10 | 100 ml | 10 | Thai | 0.875 |
| punisx 25EC | 480 ml | 25 | Vietnamese | 0.35 |
| Sherpa 25 ND | 100 ml | 25 | Vietnamese | 0.35 |
| Siker 10 | 100 ml | 10 | Thai | 0.875 |
| Starnox 350 | 100, 1000ml | 35 | Thai | 0.25 |
| Tenzo | 500 ml | 10 | Thai | 0.875 |
| Theboss | 100 ml | 10 | Thai | 0.875 |
| Tung Rin 10 EC | 480 ml | 10 | Vietnamese | 0.875 |
| Uptane | 500 ml | 35 | Thai | 0.25 |
| Vekus 10 | 100 ml | 10 | Thai | 0.875 |
| Vinbin | 500 ml | 10 | Thai | 0.875 |
| Visher 25 ND | 100 ml | 25 | Vietnamese | 0.35 |
| World Toid 10 EC | 500 ml | 10 | Thai | 0.875 |

## ដេលតាមិស្រីន - ស្រឹងបៃតង (*Deltamethrin _ GVB*)

| ឈ្មោះក្រុមហ៊ុន | បរិមាណខ្ចប់ | %កំហាប់ | ស្លាកសញ្ញា | លីត្រ/ហិចតា |
|---|---|---|---|---|
| Bai 58 | 100 ml | 40 | Vietnamese | 0.34 |
| Basoca | 100, 500 ml | 40 | Thai | 0.34 |
| BI 58 | 100, 240 ml | 50 | Vietnamese | 0.27 |
| BiAN 40EC | 100, 480, 1000 ml | 40 | Vietnamese | 0.34 |
| Bini 58 40EC | 480 ml | 40 | Vietnamese | 0.34 |
| Dibathote 40 EC | 1000 ml | 40 | Vietnamese | 0.34 |
| Dimethoate 40 EC | 1000 ml | 40 | English | 0.34 |
| Famtoy 50 | 100 ml | 50 | Vietnamese | 0.27 |
| Luxenmet 40 | 500, 1000ml | 40 | Thai | 0.34 |
| Nugor 40 EC | 480 ml | 40 | Vietnamese | 0.34 |
| Vidithoate 40 ND | 100 ml | 40 | Vietnamese | 0.34 |

## សុវត្ថិភាពនៃការប្រើប្រាស់ថ្នាំពុល

ហេតុអ្វីត្រូវគិតពីសុវត្ថិភាពពេលប្រើថ្នាំពុល ? តើថ្នាំពុល ផ្តល់ផលអាក្រក់អ្វីខ្លះ ដល់ មនុស្សនិងបរិស្ថាន ?

## សុខភាពមនុស្ស

ថ្នាំពុល អាចបង្ករគ្រោះមហន្តរាយធ្ងន់ធ្ងរដល់សង្គមមនុស្ស និងបរិស្ថាន ។ គេនិយមសង្កេតឃើញ ថ្នាំពុលបានបង្ករឱ្យ មនុស្សស្លាប់ និងបង្ករជំងឺច្រើន ជាពិសេស នៅបណ្តាលប្រទេសកំពុងអភិវឌ្ឍន៍ ។

ពុលមធ្យមៈ

- ឈឺក្បាល
- អស់កំលាំង
- ចង់ក្អួត
- បែកញើសខ្លាំង
- ត់បង់តុល្យភាព
- ព្រិលផ្នែក
- រម៉ាស់/កន្ទួលលើស្បែក



រោគសញ្ញានៃការពុលថ្នាំ

ពុលខ្លាំងៈ

- កន្ត្រាក់សាច់ដុំ
- បាត់បង់សតិអារម្មណ៍
- ប្រកាច់
- អាចស្លាប់

## ថ្នាំពុលជ្រាបចូលតាមរយៈ




រូបភាពនេះ បង្ហាញថាតើ ថ្នាំពុលអាច ជ្រាបចូលក្នុងខ្លួនមនុស្ស តាមកន្លែងណាខ្លះនៃដងខ្លួនមនុស្សយើង ។ ប្រសិនបើ មិនមាន សំភារៈការពារ ថ្នាំពុលអាច ជ្រាបចូលតាមរយៈ ស្បែកក្បាល ថ្ងាស រុញត្រចៀក ដងខ្លួនដៃ ឬជើងជាដើម ។

## ការកាត់បន្ថយ ថ្នាំជ្រាបចូលក្នុងខ្លួនយើង

បើទោះជា ថ្នាំពុលភាគច្រើន បានសរសេរជាភាសាបរទេសក៏ដោយ ប៉ុន្តែតែងតែមានរូបភាពដែលបញ្ជាក់អំពីសំភារៈគួរប្រើខណៈពេលប៉ះពាល់ និងប្រើប្រាស់ថ្នាំពុល ។

ដើម្បីធានាសុវត្ថិភាព ពេលប្រើប្រាស់ថ្នាំពុល ត្រូវប្រើសំភារៈសុវត្ថិភាពជានិច្ច ។





## ផ្នែកបរិស្ថាន

ខណៈពេលប្រើថ្នាំពុល តើថ្នាំពុលទាំងនេះ នឹងអាចទៅកន្លែងណាខ្លះ ?





បន្ទាប់ពីបានប្រើថ្នាំពុលហើយ ថ្នាំពុលទាំងនេះ នឹងអាចជ្រាបចូលទៅក្នុងដី បំភាយទៅក្នុងបរិយាកាស ជ្រាបចូលក្នុងអណ្តូង បឹង... ដែលចុងក្រោយ ថ្នាំពុលទាំងនេះអាចវិលចូលក្នុងខ្លួនមនុស្សយើងវិញតាមមធ្យោបាយផ្សេងៗ

